# សេចក្តីជូនដំណឹង

## *ការសិក្សាដោយឥតគិតថ្លៃវគ្គបណ្តុះបណ្តាល «សហគ្រិនភាព»*

ទីភ្នាក់ងារជាតិមុខរបរ និងការងារ (NEA) សហការជាមួយ ទីភ្នាក់ងារផ្តល់សេវាការងារសាធារណៈស៊ុយអែត (SPES) ក្រោមគម្រោង ការគាំទ្រដល់ការអភិវឌ្ឍជំនាញ និងការងារសម្រាប់យុវជននៅកម្ពុជា ដោយទទួលបានជំនួយហិរញ្ញវត្ថុ ពីទីភ្នាក់ងារអភិវឌ្ឍសហប្រត្តិបត្តិការអន្តរជាតិស៊ុយអែត(SIDA) នឹងធ្វើការជ្រើសរើសសិស្ស និស្សិត និងយុវជនទូទៅ ដែលកំពុងស្វែងរកឱកាសបើកអាជីវកម្ម ឱ្យចូលរួមវគ្គបណ្តុះបណ្តាល"*សហគ្រិនភាព* "ចំនួន ២៥ កន្លែង ដោយឥតគិតថ្លៃ នៅក្នុងខែមីនា ឆ្នាំ២០១៥ នៅរាជធានីភ្នំពេញ។

- **គោលបំណង**

ដើម្បីអភិវឌ្ឍ និងពង្រឹងនូវគំនិតសហគ្រិនភាពប្រកបដោយភាពប្រកួតប្រជែង និងជោគជ័យក្នុងអាជីព ឬវិជ្ជាជីវៈ

- **អត្ថប្រយោជន៍ដែលបេក្ខជនទទួលបានពីវគ្គសិក្សា**
  - ✓ ចេះសរសេរ និងរៀបចំគម្រោងអាជីវកម្ម
  - ✓ ចេះគ្រប់គ្រងធនធាន និងថវិកាប្រកបដោយប្រសិទ្ធភាព
  - ✓ យល់ដឹងអំពីយន្តការទីផ្សារ និងវិធីសាស្ត្រក្នុងការលក់
  - ✓ យល់ដឹងអំពីជំនាញពាក់ព័ន្ធផ្សេងៗទៀតក្នុងការបើកអាជីវកម្ម
  - ✓ ចូលរួមស្តាប់វាគ្មិនដែលមានបទពិសោធធ្វើការចែករំលែកបទពិសោធន៍ និងចំណេះដឹងពាក់ព័ន្ធនឹងការធ្វើអាជីវកម្ម
  - ✓ ទទួលបានវិញ្ញាបនបត្របញ្ជាក់ការសិក្សា
  - ✓ ទទួលបានការផ្តល់ប្រឹក្សាបន្ថែមសម្រាប់ការចាប់ផ្តើមអាជីវកម្មបន្ទាប់ពីវគ្គសិក្សាទី១ និងទី២
  - ✓ បណ្តុះបណ្តាលដោយគ្រូជំនាញមកពី American Academic Associates (AAA)

- **លក្ខខណ្ឌជ្រើសរើស**
  - ✓ បេក្ខជនត្រូវមានអាយុចាប់ពី ២០ ដល់៣៥ឆ្នាំ
  - ✓ បេក្ខជនត្រូវមានកម្រិតវប្បធម៌ចាប់ពីថ្នាក់មធ្យមសិក្សាទុតិយភូមិឡើងទៅ ឬជាអ្នកដែលធ្លាប់បានសិក្សា ឬកំពុងសិក្សាវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈផ្សេងៗ
  - ✓ បេក្ខជនត្រូវជាអ្នកមានការប្តេជ្ញាចិត្តខ្ពស់ក្នុងការបង្កើតអាជីវកម្មដោយខ្លួនឯង
  - ✓ បេក្ខជនត្រូវមានភាពទទួលខុសត្រូវខ្ពស់ ក្នុងការសរសេរផែនការអាជីវកម្ម ក៏ដូចជាបំពេញនូវរាល់កិច្ចការដែលបានដាក់ឱ្យធ្វើទាំងមុនពេល និងក្នុងអំឡុងពេលវគ្គបណ្តុះបណ្តាល ឲ្យបានរួចរាល់ និងដោយប្រសិទ្ធភាព
  - ✓ បេក្ខជនត្រូវតម្រូវឱ្យចូលរួមក្នុងវគ្គសិក្សាឲ្យបានពេញលេញ ដោយមិនមានអវត្តមាន។

សម្រាប់បេក្ខជនដែលមានចំណាប់អារម្មណ៍ចំពោះវគ្គនេះ សូមបំពេញពាក្យសុំចូលរៀន និងសរសេររៀបរាប់បង្ហាញពីគំនិតអាជីវកម្មរបស់ខ្លួន យ៉ាងតិច១ទំព័រ (អាចរកបាននៅក្នុងពាក្យសុំចូលរៀន) ហើយផ្ញើមកកាន់ការិយាល័យ NEAឱ្យបានមុនថ្ងៃ១៧ ខែកុម្ភៈ ឆ្នាំ២០១៥។

បញ្ជាក់៖ វគ្គសិក្សានេះនឹងប្រព្រឹត្តទៅ ចំនួន ៥ថ្ងៃ ដែលចែកចេញជា ៣វគ្គ

- វគ្គទី១ នៅថ្ងៃទី២០-២១-២២ ខែមីនា ឆ្នាំ២០១៥
- វគ្គទី២ នៅថ្ងៃទី២៥-២៦ ខែមេសា ឆ្នាំ២០១៥
- វគ្គទី៣ នៅថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៥( ប្រសិនបើផែនការអាជីវកម្មរបស់អ្នកមានសក្តានុពល នោះអ្នកនឹងត្រូវបានជ្រើសរើសឱ្យចូលរួមវគ្គទី៣ នេះជាបន្ត)
- មានផ្តល់ជូនអាហារសម្រន់ និងអាហារថ្ងៃត្រង់
- ចំពោះបេក្ខជនដែលមកពីបណ្តាខេត្ត នឹងទទួលបានប្រាក់ឧបត្ថម្ភសម្រាប់ការធ្វើដំណើរ និងស្នាក់នៅ។

- **ការចែក និងទទួលពាក្យសុំ**

កាលបរិច្ឆេទចែក និងទទួលពាក្យសុំ គឺចាប់ផ្តើមពីថ្ងៃផ្សាយដំណឹងនេះតទៅ រហូតដល់ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៥ វេលាម៉ោង ៥រសៀល ។ ពាក្យសុំអាចស្វែងរកបានតាមរយៈគេហទំព័រ www.nea.gov.kh ឬនៅតាមមជ្ឈមណ្ឌលការងារដូចខាងក្រោម៖

- **មជ្ឈមណ្ឌលការងាររាជធានីភ្នំពេញ** : អគារលេខ៣ ផ្លូវសហព័ន្ធរុស្សី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ (ស្ថិតក្នុងបរិវេនក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ)។ ទូរស័ព្ទ ០១៦ ៧៨៦ ៦៥៥, ០២៣ ៦៣៣ ៦០០២
- **មជ្ឈមណ្ឌលការងារខេត្តបាត់ដំបង** : វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនបាត់ដំបង ផ្លូវលេខ០១ ភូមិព្រែកមហាទេព សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង។ ទូរស័ព្ទ ០១៦ ៩២៦ ៦៥៥, ០៥៣ ៧៣៣ ១១១
- **មជ្ឈមណ្ឌលការងារខេត្តកំពត** : វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនកំពត ភូមិ១ឧសភា សង្កាត់កំពង់កណ្តាល ក្រុងកំពត។ ទូរស័ព្ទ ០១៦ ៥០ ៦៦ ៥៥ , ០៣៣ ២១០ ២៧៧
- **មជ្ឈមណ្ឌលការងារខេត្តសៀមរាប** : វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនសៀមរាប សង្កាត់ស្លក្រាម ក្រុងសៀមរាប ។ ទូរស័ព្ទ ០១៦ ៥៣ ៦៦ ៥៥ , ០៦៣ ២១០ ២៧៧
- **មជ្ឈមណ្ឌលការងារខេត្តស្វាយរៀង** : វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនស្វាយរៀង ភូមិមេភ្លើង សង្កាត់ស្វាយរៀង ក្រុងស្វាយរៀង។ ទូរស័ព្ទ ០១៦ ៦៤ ៦៦ ៥៥ , ០៤៤ ៧១៥ ២៧៧
- **មជ្ឈមណ្ឌលការងារខេត្តតាកែវ** : វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនតាកែវ ភូមិ៣ សង្កាត់រការក្នុង ក្រុងដូនកែវ។ ទូរស័ព្ទ ០១៦ ៦៧ ៦៦ ៥៥ , ០៣២ ២១០ ២៧៧
- **មជ្ឈមណ្ឌលការងារខេត្តកំពង់ចាម** : មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ចាម ផ្លូវលេខ០៧ចាស់ ភូមិ៧ សង្កាត់កំពង់ចាម ក្រុងកំពង់ចាម។ ទូរស័ព្ទ ០១៦ ៦៥ ៦៦ ៥៥ , ០៤២ ២១០ ២៧៧

*សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងមក លោក ពឹម សុភា តាមរយៈទូរស័ព្ទលេខ ០១១ ៦១១ ០០៩ និងអ៊ីម៉ែល pimsophea@yahoo.com ឬការិយាល័យ AAA តាមរយៈទូរស័ព្ទលេខ ០២៣ ៩៨៧ ១១៨១*